# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០៣.សរ-៩៣

## <u>សារាចរ</u>
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## <u>ផ្ញើរមក</u>
### លោក ប្រធានតុលាការខេត្ត ក្រុង ទូទាំងប្រទេស

**<u>កម្មវត្ថុ</u>:** អំពីចំណាត់ការរបស់តុលាការខេត្ត ក្រុង ក្រោយពីភាគីបានប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចរបស់ខ្លួន ។

ក្នុងរយៈកាលកន្លងទៅនេះក្រសួងយុត្តិធម៌បានសង្កេតឃើញជាញឹកញ៉ាប់ថា គូភាគីទាំងឡាយដែលត្រូវបានតុលាការខេត្ត ក្រុង សម្រេចសេចក្តីចេញជាសាលក្រមរួចហើយ ហើយមានភាគីម្ខាង ឬទាំងសងខាងមិនសុខចិត្តបានប្តឹងឧទ្ធរណ៍ពីសេចក្តីសម្រេចនោះ ភាគីម្ខាង ឬទាំងសងខាងតែងប្រើសិទ្ធិរំលោភ ដូចជាសង់សំណង់ឬរុះរើសំណង់ ឬកាន់កាប់ដីធ្លីដែលកំពុងមានទំនាស់គ្នាជាដើម ។

ក្រសួងសូមរំលឹកដល់ប្រធានតុលាការខេត្ត ក្រុងទាំងអស់ថា គ្រប់សេចក្តីសម្រេចរបស់តុលាការខេត្ត ក្រុង ដែលត្រូវបានភាគីម្ខាងឬទាំងសងខាងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ សេចក្តីសម្រេចនោះមិនអាចយកទៅអនុវត្តបានឡើយបានន័យថា ត្រូវរក្សាទុកវត្ថុដែលមានទំនាស់ឲ្យនៅភាពដូចដើមជានិច្ច ដ៏រាបណាសាលាឧទ្ធរណ៍មិនទាន់បានសម្រេចអំពីរឿងនោះនៅឡើយ ។

ម្យ៉ាងទៀតក្នុងការសម្រេចសេចក្តីចេញជាសាលក្រម ចៅក្រមជំនុំជម្រះក្តីទាំងឡាយត្រូវតែរំលឹកក្នុងសេចក្តីសម្រេចរបស់ខ្លួនថា បណ្តឹងឧទ្ធរណ៍ត្រូវផ្អាកការអនុវត្តសាលក្រមរបស់តុលាការខេត្ត ក្រុង ។

ក្នុងករណីមានភាគីណាមួយបានប្តឹងឧទ្ធរណ៍ពីសាលក្រមនោះរួចហើយ ហើយភាគីម្ខាងទៀតនៅតែរំលោភដោយយកសាលក្រមនោះទៅអនុវត្ត ឬធ្វើឲ្យប្រែភាពដើមនៃវត្ថុទំនាស់នោះ ប្រធានតុលាការត្រូវតែចេញដីកាហាមឃាត់ជននោះអំពីអំពើខុសច្បាប់ ដែលជននោះបានប្រព្រឹត្តហើយបង្គាប់ឲ្យជននោះផ្អាកនូវសកម្មភាពរបស់ខ្លួនជាបន្ទាន់ ។

នៅពេលសាលាឧទ្ធរណ៍ចាប់ដំណើរការ នោះឧប្បត្តិហេតុទាំងឡាយដែលកើតចេញពីការអនុវត្តសាលក្រមរបស់តុលាការខេត្ត ក្រុង ដែលភាគីបានប្តឹងឧទ្ធរណ៍នោះជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ ។

ក្រសួងសង្ឃឹមថា សេចក្តីណែនាំខាងលើនេះអាចជួយដល់ប្រធានតុលាការខេត្ត ក្រុង ក្នុងការទប់ស្កាត់នូវអំពើរំលោភច្បាប់ដែលកើតមានជារឿយៗ ពីបណ្តាភាគីទាំងឡាយក្នុងរឿងក្តី ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

<u>ចម្លងជូន</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ
-តុលាការកំពូល និងអយ្យការ
-សាលាឧទ្ធរណ៍ និងអយ្យការ
-អភិបាលខេត្ត ក្រុង
-ដើម្បីជ្រាប